# ជំងឺសើស្បែក

ជំពូកទី ១៥

ជំងឺសើស្បែកមួយចំនួនកើតឡើងដោយសារជំងឺ ឬការរោលផ្សេងៗដែលប៉ះពាល់តែទៅលើស្បែក ដូចជាស្រែងការឡើងកន្ទួលក្រហមរមាស់ដោយសារការរោលដោយកន្ទបទ្រាប់ទឹកនោម ឬការកើតឫស ជាដើម។ ជំងឺសើស្បែកដទៃទៀត គឺជារោគសញ្ញានៃជំងឺដែលប៉ះពាល់ដល់ខ្លួនប្រាណទាំងមូល ដូចជា ការមានស្នាមអុចៗក្រហមក្នុងជំងឺកញ្ជ្រឹល ឬការមានដំបៅ ការមានស្នាមកន្ទួលក្រហមស្ងួតនៅលើស្បែក ក្នុងជំងឺខ្វះអាហារូបត្ថម្ភ (កង្វះអាហារូបត្ថម្ភ)។ ការមានដំបៅឬបញ្ហាស្បែកខ្លះ អាចជារោគសញ្ញានៃជំងឺធ្ងន់ធ្ងរ ដូចជា ជំងឺរបេង ស្វាយ ឬឃ្លង់។

ជំពូកនេះនឹងពិភាក្សាអំពីជំងឺសើស្បែកដែលកើតឡើងញឹកញាប់នៅតាមជនបទតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក៏ដោយ មានជំងឺសើស្បែកជាច្រើនប្រភេទ។ ជំងឺសើស្បែកខ្លះ មើលទៅមានលក្ខណៈដូចគ្នាយ៉ាងខ្លាំង ដែលធ្វើឲ្យពិបាកនឹងញែកឲ្យដាច់ពីគ្នាណាស់ ប៉ុន្តែវាអាចមានមូលហេតុផ្សេងគ្នា និងត្រូវការការព្យាបាលជាក់លាក់ខុសៗគ្នា។

**ប្រសិនបើជំងឺសើស្បែកមានសភាពធ្ងន់ធ្ងរ ឬកាន់តែមានសភាពធ្ងន់ធ្ងរ ទោះបីជាបានទទួលការព្យាបាលក៏ដោយនោះ ត្រូវស្វែងរកជំនួយពីគ្រូពេទ្យ។**

## ក្បួនទូទៅសម្រាប់ព្យាបាលជំងឺសើស្បែក

ថ្វីបើជំងឺសើស្បែកមួយចំនួន ត្រូវការការព្យាបាលជាក់លាក់ក្តី ក៏នៅមានមធ្យោបាយទូទៅខ្លះដែរ ដែលអាចជួយបាន ៖

### ក្បួនទី ១

បើកន្លែងស្បែកដែលមានបញ្ហានោះ **ក្តៅ** និងមានការឈឺចាប់ ឬមានជ្រាបខ្ទុះ ព្យាបាលវាដោយប្រើ**កម្តៅ**។ ស្អំវាដោយក្រណាត់ជ្រលក់ទឹកក្តៅ។



### ក្បួនទី ២

បើកន្លែងស្បែកដែលមានបញ្ហានោះ រមាស់ចាក់ឆៀបៗ ឬមានជ្រាបទឹកថ្លាៗ ស្អំវាដោយក្រណាត់ជ្រលក់ទឹកត្រជាក់។



**ក្បួនទី១ (ការពន្យល់លម្អិត)**

បើស្បែកបង្ហាញរោគសញ្ញានៃការបង្ករោគធ្ងន់ធ្ងរ ដូចជា ៖

- សញ្ញានៃការរលាក(ការឡើងក្រហមនៅស្បែកដែលនៅជុំវិញកន្លែងដែលមានបញ្ហានោះ)។
- ការហើម
- ការឈឺចាប់
- ការមានកម្តៅ (មានអារម្មណ៍ថាក្តៅ)
- មានខ្ទុះ

ត្រូវធ្វើដូចខាងក្រោមនេះ ៖



- ♦ ដាក់ផ្នែកដែលមានបញ្ហានោះឲ្យនៅស្ងៀម និងលើកវាឲ្យខ្ពស់បន្តិច (ដាក់ឲ្យខ្ពស់ជាងផ្នែកដទៃទៀតនៃខ្លួនប្រាណ)
- ♦ ស្អំដោយក្រណាត់ជ្រលក់ទឹកក្តៅ
- ♦ បើការបង្ករោគមានសភាពធ្ងន់ធ្ងរ ឬអ្នកជំងឺមានគ្រុនក្តៅ ឲ្យថ្នាំអង់ទីប៊ីយ៉ូទិក (ប៉េនីស៊ីលីន ឬស៊ុលហ្វូណាមីដ ឬអេរីត្រូមីស៊ីន)។

រោគសញ្ញាគ្រោះថ្នាក់រួមមាន ៖ ការហើមកូនកណ្តុរ ការមានស្នាមខ្សែក្រហមឬខ្មៅនៅលើកន្លែងដែលមានការបង្ករោគនោះ ឬការមានក្លិនអាក្រក់។ បើបញ្ហានេះមិនធូរស្រាល ដោយការព្យាបាល ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ហើយរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

**វិធីទី២ (ការពន្យល់លម្អិត)**

បើស្បែកដែលមានបញ្ហានោះ កើតមានពងទឹក ឬមានក្រមរ មាន ជ្រាបទឹកថ្លាៗ រមាស់ចាប់ឆៀបៗ ឬក្រហាយ ធ្វើដូចតទៅនេះ៖



- ♦ ស្អំដោយក្រណាត់ត្រាំទឹកត្រជាក់ លាយជាមួយនឹងទឹក ខ្មេះស (ទឹកខ្មេះ២ស្លាបព្រាបាយ និងទឹកឆ្អិន ១កា)។
- ♦ នៅពេលស្បែកដែលមានបញ្ហានោះមានការធូរស្រាលហើយលែងមានជ្រាបទឹកថ្លាៗ ហើយមានការដុះស្បែក ថ្មីឡើងវិញ លាបសើៗដោយម្សៅលាយជាមួយទឹក (ទឹក១ភាគ ម្សៅ១ភាគ)។
- ♦ នៅពេលកំពុងមានការជាសះស្បើយ ហើយស្បែកថ្មីក៏ចាប់ក្រាស់ឡើងៗ ឬរបក រឹតជាមួយនឹងប្រេងរុក្ខជាតិ ឬប្រេងលាបខ្លួនដើម្បីឲ្យវាទន់។

**ក្បួនទី ៣**

បើកន្លែងស្បែកដែលមានបញ្ហានោះ ស្ថិតនៅលើផ្នែកណាមួយនៃរាងកាយ ដែលតែងតែត្រូវកម្ដៅថ្ងៃជាញឹកញាប់ ការពារកន្លែងនោះពីកម្ដៅថ្ងៃ។



**ក្បួនទី ៤**

បើកន្លែងដែលមានបញ្ហានោះ តែងតែត្រូវបានគ្របដណ្ដប់ដោយសំលៀកបំពាក់ ដាក់វាឲ្យត្រូវពន្លឺថ្ងៃដោយផ្ទាល់រយៈពេល១០ទៅ២០នាទី ២ឬ៣ដងក្នុង១ថ្ងៃ។



# សេចក្ដីណែនាំអំពីការស្អំដោយក្រណាត់ក្ដៅ



១. ដាំទឹកឲ្យពុះ ហើយទុកឲ្យត្រជាក់រហូតដល់ អ្នកអាចដាក់ដៃក្នុងទឹកនោះបាន។

២. បត់ក្រណាត់ស្អាតមួយដុំឲ្យមានទំហំធំជាងទំហំផ្ទៃស្បែកដែលអ្នកចង់ព្យាបាលនោះបន្តិច ហើយជ្រលក់ក្រណាត់នោះក្នុងទឹកក្ដៅ រួចពូតទឹកចេញ។

៣. ដាក់ក្រណាត់នោះស្អំលើស្បែកដែលមានបញ្ហានោះ។

៤. គ្របក្រណាត់នោះដោយផ្ទាំងប្លាស្ទិកស្ដើងមួយសន្លឹក ឬដោយក្រដាស់ស្ដើងភ្លឺៗ។

៥. រុំវាដោយកន្សែងមួយ ដើម្បីឲ្យក្ដៅបានយូរ។

៦. ដាក់កន្លែងដែលមានបញ្ហានោះឲ្យឡើងខ្ពស់បន្តិច។

៧. នៅពេលក្រណាត់ចាប់ផ្ដើមត្រជាក់ ជ្រលក់វាក្នុងទឹកក្ដៅវិញ រួចធ្វើដូចមុនឡើងវិញ។

# ជំងឺសើស្បែក (ការណែនាំអំពីរបៀបសំគាល់ជំងឺ)

| បើស្បែកមាន | និងមើលទៅដូចជា | អ្នកប្រហែលជាមានជំងឺ | មើលទំព័រ |
|---|---|---|---|
| ដំបៅតូចៗ ដូចមុន  | ពងទឹកល្អិតៗ ឬដំបៅដែលរមាស់ យ៉ាងខ្លាំង ដំបូងនៅចន្លោះម្រាមដៃ កដៃ ឬចង្កេះ  | កមរមាស់ | ១៩៩ |
| | មុនឬដំបៅមានខ្ទុះ ឬរលាក ដែលច្រើន បណ្ដាលមកពីការអេះពេលសត្វល្អិត ខាំ។ អាចបណ្ដាលឲ្យមានហើមកូនកណ្ដុរ  | ការបង្ករោគដោយ បាក់តេរី | ២០១ |
| | ដំបៅដែលមាននៅជាច្រើន កន្លែង ដែលមានក្រមរពណ៌ លឿង រលោង  | ពងបែក (ការបង្ករោគ ដោយបាក់តេរី) | ២០២ |
| | មុននៅលើមុខមនុស្សជំទង់ ជួនកាល នៅលើទ្រូងនិងខ្នង ភាគច្រើន មានដុំខ្ទុះតូចៗ  | មុន | ២១១ |
| | ដំបៅនៅលើប្រដាប់ភេទ  គ្មានរមាស់ ឬការឈឺចាប់ | ស្វាយ ជំងឺកាមរោគ | ២៣៧ ២៣៨ |
| | មានការឈឺចាប់ និងខ្ទុះ | ដំបៅទាមឡា | ៤០៣ |

| | | | |
|---|---|---|---|
| ដំបៅធំៗ ឬ ដំបៅស្បែក  | ដំបៅធំរ៉ាំរ៉ៃ(មិនជាសះ)រុំពទ្ធ័ដោយស្បែកពណ៌ស្វាយ នៅលើឬនៅក្បែរកជើងមនុស្សចាស់ដែលមាន សរសៃវ៉ែនរីក  | ដំបៅដែលបណ្ដាលមក ពីឈាមរត់មិនល្អ(អាច ជាជំងឺទឹកនោមផ្អែម) | ២១៣ ១២៧ |
| | ដំបៅនៅលើឆ្អឹងឬសន្លាក់នៃមនុស្ស ឈឺធ្ងន់ដែលក្រោកពីគ្រែមិនរួច  | ដំបៅគ្រែ | ២១៤ |
| | ដំបៅដែលមានការបាត់បង់ញាណដឹងនៅ ជើង ឬដៃ(សូម្បីចាក់និងម្ជុលក៏មិនឈឺដែរ)  | ជំងឺឃ្លង់ | ១៩១ |
| | មានដុំពក បន្ទាប់មកក្លាយជាដំបៅដែលមិន ជាសះ ដែលមាននៅលើរាងកាយ ឬផ្ទៃមុខ  | ឡេអ៊ីសម៉ានីយ៉ាស៊ីស | ៤០៦ |

| | | | |
|---|---|---|---|
| ដុំពកនៅ ក្រោមស្បែក  | ការហើម និងមានការ ឈឺចាប់ និងក្ដៅ ដែលអាចធ្លាយហើយហូរខ្ទុះ  | អាប់សែ ឬបូស | ២០២ |
| | ដុំពកដែលមានការឈឺចាប់និងក្ដៅ នៅដោះរបស់ស្ត្រីដែលបំបៅដោះកូន  | រលាកដោះ(ការបង្ក រោគដោយបាក់តេរី) អាចជាមហារីក | ២៧៨ ២៧៩ |
| | ដុំពកដែលចេះតែធំឡើងៗ តាមធម្មតា មិនឈឺទេនៅពេលដំបូង  | មហារីកដោះ (មើលកូនកណ្ដុរផង) | ២៧៩ ៨៨ |
| | ដុំពកមួយឬច្រើននៅលើក្បាល ក ឬនៅខ្លួន ផ្នែកខាងលើ (ឬនៅផ្នែកកណ្ដាលដងខ្លួន និងភ្លៅ)  | ជំងឺអុងកូសែកូស៊ីស (មើលកូនកណ្ដុរផង) | ២២៧ ៨៨ |

# ការណែនាំអំពីរបៀបសំគាល់ជំងឺ

| បើស្បែកមាន | និងមើលទៅដូចជា | | អ្នកប្រហែលជាមានជំងឺ | មើលទំព័រ |
|---|---|---|---|---|
| ហើមកូនកណ្ដុរ  | មានកូនកណ្ដុរនៅចំហៀងកញ្ចឹងក ដែលបែកជាបន្តបន្ទាប់ ហើយមានដំបៅ |  | ស្រែញ (ប្រភេទមួយនៃជំងឺរបេង) | ២១២ |
| | មានកូនកណ្ដុរនៅក្រលៀន ដែលបែកជាបន្តបន្ទាប់ ហើយមានដំបៅ |  | ទាមឡា | ២៣៨<br>៤០៣ |

| | | | | |
|---|---|---|---|---|
| ស្នាមកន្ទួលធំៗ  ពណ៌ខ្មៅ | មានស្នាមកន្ទួលពណ៌ខ្មៅនៅថ្ងាស់ និងថ្ពាល់នៃស្ត្រីមានផ្ទៃពោះ |  | ជាំមុខ នៃស្ត្រីមានផ្ទៃពោះ | ២០៧ |
| | មានរបកស្បែកដូចជាមានការរលាកដោយកម្ដៅថ្ងៃ នៅលើដៃ ជើង ក ឬផ្ទៃមុខ |  | ប្រេះបែកស្រការ (កង្វះអាហារូបត្ថម្ភ) | ២០៨<br>២០៩ |
| | ចំណុចពណ៌ខ្មៅនៅលើស្បែក ឬក្នុងមាត់ ដែលដំបូងតូចៗ បន្ទាប់មកធំទៅៗ។ ពុំមានការឈឺចាប់ទេ |  | មហារីកស្បែក (មហារីកទាក់ទងនឹងជំងឺអេដស៍) | ៣០៩-<br>៤០១ |
| | មានចំណុចពណ៌ស្វាយ ឬដំបៅរបកស្បែកលើកុមារដែលមានហើមជើង |  | កង្វះអាហារូបត្ថម្ភ | ២០៨<br>២០៩ |
|  ពណ៌ស | ផ្ទាំងមូល ឬមានរាងមិនទៀងទាត់ នៅលើខ្លួន ឬមុខ ជាពិសេសចំពោះកុមារ |  | កើតត្លី | ២០៦ |
| | ផ្ទាំងពណ៌ស ពិសេសនៅលើ ដៃ ជើង ឬ បបូរមាត់  | ដែលចាប់ផ្ដើមដោយចំណុចពណ៌ក្រហម ឬពណ៌ខៀវ | ពពាល (ការបង្ករោគ) | ២០៧ |
| | | ដែលចាប់ផ្ដើមដោយគ្មានសញ្ញាដទៃទៀត | ឃ្លង់ល្មៅ (ការបាត់បង់ពណ៌ស្បែក) | ២០៧ |
|  ពណ៌ក្រហម | ផ្ទាំងពណ៌ក្រហម ឬផ្ទាំងពងទឹកតូចៗនៅលើថ្ពាល់ ឬខាងក្រោយជង្គង់និងកែងដៃនៃកុមារតូចៗ |  | តាអក | ២១៦ |
| | ផ្ទាំងក្រហមក្ដៅនិងឈឺចាប់ ដែលរាលដាលយ៉ាងឆាប់រហ័ស |  | ពងបែក(រលាកស្បែក ឬការបង្ករោគធ្ងន់ធ្ងរដោយបាក់តេរី) | ២១២ |
| | ផ្ទៃពណ៌ក្រហម នៅចន្លោះគល់ភ្លៅរបស់ទារក |  | រលាកដោយសារការពេលដោយកន្ទបនោម ឬដោយកម្ដៅ | ២១៥ |
| | ផ្ទាំងពណ៌ក្រហម លាយសនៅតាមផ្នត់ស្បែក |  | ការបង្ករោគនៅស្បែកដោយមេរោគផ្សិត (ម៉ូនីលីយ៉ាសីស) | ២៤២ |
| ពណ៌ក្រហម ឬប្រផេះ | ផ្ទាំងពណ៌ក្រហមឬប្រផេះ ជាពិសេសលើកែងដៃនិងជង្គង់ មានសភាពក្រាំរ៉ែ |  | សូរីយ៉ាស៊ីស (ឬ ជួនកាលរបេង) | ២១៦<br>២១២ |

# ការណែនាំអំពីរបៀបសំគាល់ជំងឺ

| បើស្បែកមាន | និងមើលទៅដូចជា | អ្នកប្រហែលជាមានជំងឺ | មើលទំព័រ |
|---|---|---|---|
| ឬស  | ឬសធម្មតា មិនធំពេក  | ឬសធម្មតា (ការបង្ក រោគដោយវីរុស) | ២១០ |
| | ដុំដូចឬសនៅលើប្រដាប់ភេទបុរសស្ត្រី ឬជុំវិញរន្ធគូថ  | សិរមាន់ | ៤០២ |
| | ដុំដូចឬស នៅលើផ្នែកផ្សេងទៀតនៃរាងកាយ | យ៉ស៍ | ២០២ |
| | ឬសធំ (ធំជាង១ស.ម) ភាគច្រើននៅលើ ដៃឬជើង  | ប្រភេទម្យ៉ាងនៃជំងឺ របេងស្បែក | ២១២ |
|  | ផ្ទាំងមូលតូចៗ ដែលបន្តរីកធំ ឬរាលដាល ហើយរមាស់  | ស្រែង (ការបង្ករោគ ដោយមេរោគផ្សិត) | ២០៥ |
| ស្រែង | ផ្ទាំងមូលធំៗ មានគែមក្រាស់មិនរមាស់  | ជំងឺស្វាយក្នុងដំណាក់ កាលធ្ងន់ធ្ងរ | ២៣៧ |
| | ផ្ទាំងមូលធំៗពណ៌សឬពណ៌ស្រាល ហើយក្លាយជាស្ពឹកនៅកណ្តាល (ការចាក់ដោយម្ជុលក៏មិនឈឺដែរ)  | ឃ្លង់ | ១៩១ |
|  | ផ្ទាំងមូលតូចៗ ជួនកាលមាន រន្ធតូច មួយនៅកណ្តាល ឃើញ មាននៅសៀតផ្កា ច្រមុះ ឬក   | មហារីកស្បែក | ២១១ |
|  កន្ទាលត្រអាក | ផ្ទាំងកន្ទួលរមាស់ខ្លាំង (វាអាចចេញ ហើយបាត់វិញយ៉ាងរហ័ស)  | ប្រតិកម្មទំនាស់ | ២០៣ |
|  | ពងទឹក រមាស់ខ្លាំង និងហូរទឹករងៃ  | រលាកស្បែក (ដូចជា ការពុលដោយថ្នាំពុល) | ២០៤ |
| ពងទឹក  | ពងទឹកតូចៗពេញខ្លួនប្រាណ ដោយមានគ្រុនក្តៅ  | អុតស្វាយ | ៣១១ |
|  | ផ្ទាំងពងទឹកដែលមានការឈឺចាប់ ដែល ចេញនៅតែផ្នែកម្ខាងនៃរាងកាយ ភាគច្រើនចេញជាខ្សែៗ ឬជាចង្កោម  | រើមធំ | ២០៤ |
| | ដំបៅក្លិនអាក្រក់ ពណ៌ប្រផេះ ឬពណ៌ខ្មៅ ដោយមានពងទឹក និងពពុះខ្យល់ដែលបន្តរាលដាល  | ដំបៅរលួយ (ការបង្ក រោគយ៉ាងធ្ងន់ធ្ងរដោយ បាក់តេរី) | ២១៣ |
|  ចំណុចក្រហមតូចៗ ឬកន្ទួលពេញខ្លួន និងមានគ្រុនក្តៅ | កន្ទួលក្រហមៗ ពេញខ្លួនទាំងមូល ដែលកើតលើកុមារដែលមានជំងឺធ្ងន់  | កញ្ជ្រឹល | ៣១១ |
|  | បន្ទាប់ពីគ្រុនក្តៅពីរបីថ្ងៃ ចំណុច តូចៗពណ៌ផ្កាឈូក ចេញនៅលើ ខ្លួន ហើយអ្នកជំងឺមានសភាពធ្ងន់ធ្ងរ  | គ្រុនពោះវៀន | ១៨៨ |

# កមរមាស់

ជំងឺនេះកើតជាញឹកញាប់លើកុមារ។ វាបណ្តាលឲ្យដុំពកតូចៗដែលរមាស់យ៉ាងខ្លាំង ហើយអាចចេញពេញខ្លួន ប៉ុន្តែភាគច្រើនចេញនៅ ៖






ដំបៅតូចៗដែលរមាស់ នៅលើលិង្គ និងពងស្វាស របស់កុមារតូចៗ ច្រើនតែជាកមរមាស់។

កមរមាស់បណ្តាលមកពីសត្វល្អិតស្រដៀងនឹងសត្វចៃដែលធ្វើរូងនៅក្រោមស្បែក។ វាឆ្លងរាលដាលតាមរយៈការប៉ះពាល់កន្លែងដែលកើតកមរមាស់នេះ ឬតាមសំលៀកបំពាក់ និងសម្ភារៈគ្រែគេង។ ការអេះអាចបណ្តាលឲ្យមានការបង្ករោគ ហើយបង្កើតបានជាដំបៅដែលមានខ្ទុះ ហើយជួនកាលមានហើមកូនកណ្តុរ ឬមានគ្រុនក្តៅ។

*វិធីព្យាបាល*

- ប្រសិនបើនរណាម្នាក់កើតកមរមាស់ នោះសមាជិកទាំងអស់ក្នុងគ្រួសារ គួរទទួលការព្យាបាល។
- អនាម័យផ្ទាល់ខ្លួន មានសារសំខាន់ណាស់។ ងូតទឹក និងផ្លាស់ខោអាវជារៀងរាល់ថ្ងៃ។
- កាត់ក្រចកដៃឲ្យខ្លី ដើម្បីកាត់បន្ថយការឆ្លងរាលដាល និងការបង្ករោគ។
- បោកខោអាវនិងសម្ភារៈគ្រែគេងទាំងអស់ ឬកាន់តែល្អ គឺស្ងោរសំលៀកបំពាក់និងសម្ភារៈទាំងនោះ ហើយហាលវាឲ្យត្រូវពន្លឺថ្ងៃ។
- ធ្វើក្រមួនឬប្រេងលាបខ្លួនពីឡាំងដាន(ទំ.៣៧៣) និងវ៉ាស៊ីលីន(ទំ.៣៧១)។ នៅប្រទេសជាច្រើន ឡាំងដានត្រូវបានគេលក់។

  លាងសម្អាតខ្លួនប្រាណឲ្យស្អាតដោយប្រើសាប៊ូ និងទឹកក្តៅ។

  កម្តៅវ៉ាស៊ីលីន(ឬប្រេងលាបខ្លួន)១៥ភាគ លាយជាមួយឡាំងដាន១ភាគ។ លាបក្រមួននេះឲ្យសព្វខ្លួនប្រាណ (កុំលាបមុខ តែបើមុខមានកមរមាស់ដែរ ត្រូវលាបវាផង)។ ទុកវាមួយថ្ងៃ ហើយងូតទឹក លាងវាចេញឲ្យស្អាត។ បន្ទាប់ពីព្យាបាលរួច ស្លៀកសំលៀកបំពាក់ស្អាត និងប្រើប្រាស់សម្ភារៈគ្រែគេងដែលស្អាតដែរ។ មួយអាទិត្យក្រោយមក ព្យាបាលរបៀបនេះម្តងទៀត។
- ជំនួសឲ្យក្រមួនឬប្រេងលាបខ្លួននេះ អ្នកអាចបន្តក់ឡាំងដាន៤ដំណក់ លើផ្លែក្រូចឆ្មា១ចំហៀងក៏បាន។ ទុកវារយៈពេល៥នាទី បន្ទាប់មក យកក្រូចឆ្មានោះជូតខ្លួនទាំងមូល លើកលែងតែមុខ ដោយចាប់ផ្តើមពីកន្លែងដែលមានរមាស់។



**ចំណាំ ៖** ក្រមួនឬទឹកថ្នាំដែលមានដាក់លក់ដូចជា ហ្គាម៉ាបង់សែន អិចស្ពាខ្លរីដ ឬបង់ហ្ស៊ីល បង់ហ្សូអាត អាចសម្លាប់ចៃបានដែរ តែវាមានតម្លៃថ្លៃពេក។

*ប្រយ័ត្ន ៖* ឡាំងដានអាចបណ្តាលឲ្យពុលបើប្រើញឹកញាប់ពេក។ កុំលាបលើសពី១ដងក្នុង១អាទិត្យ ហើយងូតទឹកសម្អាតឲ្យបានល្អនៅថ្ងៃបន្ទាប់។ មិនត្រូវប្រើថ្នាំឡាំងដានចំពោះទារកអាយុក្រោម១ឆ្នាំទេ។

- ប្រសិនបើអ្នកមិនអាចរកឡាំងដាន ឬថ្នាំទាំងនេះបាន លាយស្ពាន់ធរ័ និងខ្លាញ់ និងប្រេងលាបខ្លួន ហើយលាបលើស្បែក។ ប្រើស្ពាន់ធរ័១ភាគ និងប្រេង១០ភាគ។

## ចៃ 



មានបីប្រភេទ ៖ ចៃក្បាល ចៃខ្លួន និងចៃនៅរោមថ្វាសប្រដាប់ភេទ។ ចៃធ្វើឲ្យរមាស់ ហើយជួនកាលវាធ្វើឲ្យមានការបង្ករោគនៅស្បែក និងហើមកូនកណ្តុរ។ ដើម្បីកុំឲ្យមានចៃ រក្សាអនាម័យផ្ទាល់ខ្លួន។ បោកគក់សំលៀកបំពាក់និងសម្ភារៈគ្រែគេងឲ្យបានញឹកញាប់ ហើយហាលឲ្យត្រូវកម្តៅថ្ងៃ។ ងូតទឹកនិងកក់សក់ឲ្យបានញឹកញាប់។ ពិនិត្យសក់ក្បាលរបស់កុមារ។ ប្រសិនបើមានចៃ ព្យាបាលភ្លាម។ កុំឲ្យកុមារដែលមានចៃ ដេកជាមួយអ្នកឯទៀត។

*វិធីព្យាបាល*

**ចំពោះចៃក្បាល និងចៃនៅតាមរោមថ្វាសប្រដាប់ភេទ** ៖ ភាគច្រើនអ្នកអាចបំបាត់ចៃបានដោយមិនចាំបាច់ប្រើថ្នាំអ្វីទេ ដោយគ្រាន់តែកក់សក់ឲ្យស្អាតជាមួយសាប៊ូធម្មតា រយៈពេលដប់នាទី។ លាងសក់ឲ្យស្អាត ហើយសិតវាដោយក្រាសដែលមានធ្មេញញឹក។ បន្តធ្វើយ៉ាងនេះ រយៈពេល១០ថ្ងៃ។



- បើចាំបាច់ ធ្វើសាប៊ូកក់សក់ពីឡាំងដាន(ទំ.៣៧៣) ទឹក និងសាប៊ូ (ឡាំងដាន១ភាគ ជាមួយទឹក១០ភាគ)។ ប្រយ័ត្ន ៖ ឡាំងដានជាថ្នាំពុល! កក់សក់ដោយប្រយត្ន័កុំឲ្យឡាំងដានចូលភ្នែកឬមាត់។ ទុកវារយៈពេល១០នាទី រួចលាងជម្រះវាឲ្យស្អាត។ មួយអាទិត្យក្រោយមកធ្វើដូចនេះម្តងទៀត។
- ដើម្បីកម្ចាត់ពងចៃ ត្រាំសក់ជាមួយទឹកខ្មេះលាយទឹកក្តៅ (ទឹកខ្មេះ១ភាគ ទឹក១ភាគ) រយៈពេលប្រហែលកន្លះម៉ោង បន្ទាប់មកសិតសក់ឲ្យបានល្អដោយក្រាសដែលមានធ្មេញញឹក។

**ចំពោះចៃខ្លួន** ៖ ត្រាំខ្លួនទាំងមូលក្នុងទឹកក្តៅជារៀងរាល់ថ្ងៃ រយៈពេល១០ថ្ងៃ។ ក្រោយពេលងូតទឹកម្តងៗ លាងសម្អាតរាងកាយឲ្យសព្វ ជាមួយសាប៊ូ បន្ទាប់មកលាងជម្រះឲ្យបានល្អ។ ប្រើក្រាសដែលមានធ្មេញញឹកសិតនៅកន្លែងដែលមានរោម។ បើចាំបាច់ ព្យាបាលដូចកមររមាស់ដែរ។ រក្សាអនាម័យសំលៀកបំពាក់ និងសម្ភារៈគ្រែគេង។

## សង្កើច 



សង្កើចគឺជាពពួកសត្វល្អិតតូចៗដែលវារ និងលាក់ខ្លួននៅក្នុងពូក សម្ភារៈគ្រែគេង គ្រឿងសង្ហារឹម និងជញ្ជាំង។ ជាធម្មតា ពួកវាចេញមកខាំនៅពេលយប់។ ស្នាមខាំច្រើនឃើញជាជួរ ឬជាក្រុម។

ដើម្បីកម្ចាត់សង្កើច បោកគក់សម្ភារៈគ្រែគេង និងចាក់ទឹកក្តៅនៅលើគ្រែ និងតាមគែមគ្រែ។ ចាក់រាយស្ពាន់ធ័រនៅលើពូក ទូដាក់ខោអាវ និងនៅតាមកម្រាលផ្សេងៗ តែមិនត្រូវប្រើវត្ថុឬសម្ភារៈដែលចាក់ស្ពាន់ធ័រពីលើនេះរយៈពេល៣អាទិត្យ។ ត្រូវប្រាកដថាបានលាងសម្អាតឲ្យបានល្អនូវម្សៅស្ពាន់ធ័រទាំងនោះ មុននឹងយកមកប្រើវិញ។

ដើម្បីបង្ការសង្កើច ដាក់សម្ភារៈគ្រែគេង ពូក កន្ទេល និងគ្រែ ហាលថ្ងៃឲ្យបានញឹកញាប់។

## តឹកកែ(សត្វល្អិត)ខាំ

ការបង្ករោគដ៏គ្រោះថ្នាក់មួយចំនួន ឬពិការភាព ត្រូវបានចម្លងដោយសារតឹកកែខាំ។ ប៉ុន្តែ ការចាប់វាចេញដោយប្រុងប្រយ័ត្ន ក្នុងរយៈពេលពីរបីម៉ោង តែងតែអាចបង្ការបញ្ហាទាំងនេះបាន។ ដូចនេះ ត្រូវពិនិត្យមើលរាងកាយទាំងមូលឲ្យបានហ្មត់ចត់ បន្ទាប់ពីមានការដើរនៅក្នុងតំបន់ដែលសំបូរតឹកកែ។

នៅពេលចាប់តឹកកែណាមួយដែលខាំជាប់យ៉ាងមាំ ចេញពីខ្លួន ប្រយត្ន័កុំឲ្យក្បាលរបស់វានៅជាប់ក្នុងស្បែក ព្រោះវាអាចបណ្ដាលឲ្យមានការបង្ករោគ។ មិនត្រូវចាប់ទាញខ្លួនតឹកកែទេ។ ដើម្បីចាប់វាចេញ ៖

- ត្រូវប្រើដង្កៀបចាប់តឹកកែឲ្យបានជិតដល់មាត់វាបំផុត គឺត្រង់កន្លែងដែលជាប់នឹងស្បែក។ (កុំព្យាយាមច្របាច់ពោះដែលកំពុងប៉ោងរបស់វា)។ ទាញថៃតឹកកែចេញដោយថ្នមៗ ប៉ុន្តែត្រូវកាន់ឲ្យជាប់។ មិនត្រូវប៉ះពាល់តឹកកែដែលបានទាញចេញនោះទេ។ ដុតវាចោល។
- ឬ យកភ្លើងបារីដាក់ជិតវា។ ឬដាក់អាល់កុលលើវា។



ដើម្បីចាប់តឹកកែតូចៗចេញ ប្រើថ្នាំណាមួយក្នុងចំណោមថ្នាំទាំងឡាយដែលបានណែនាំសម្រាប់ព្យាបាលជំងឺកមរមាស់(មើលទំ.១៩៩)។ ដើម្បីបន្ថយការឈឺចាប់ឬការរមាស់ដែលបណ្ដាលមកពីតឹកកែខាំ លេបថ្នាំអាស្ពីរីន ហើយធ្វើតាមការណែនាំសម្រាប់ព្យាបាលរមាស់ នៅទំ.២០៣។

ដើម្បីជួយបង្ការតឹកកែកុំឲ្យខាំអ្នក លាបម្សៅស្ពាន់ធ័រលើខ្លួនប្រាណអ្នកមុននឹងទៅស្រែចំការ ឬចូលក្នុងព្រៃ។ ជាពិសេសលាបកជើង កដៃ ចង្កេះ និងក្រោមក្លៀក។

## ដំបៅតូចៗដែលមានខ្ទុះ

ការបង្ករោគលើស្បែកដែលមានទម្រង់ជាដំបៅតូចៗហើយមានខ្ទុះ ជាញឹកញាប់បណ្ដាលមកពីការអេះដោយសារសត្វល្អិតទិចឬខាំ កមរមាស់ ឬការរលាត់ដោយក្រចកដៃកខ្វក់។



*វិធីព្យាបាល និងវិធីបង្ការ ៖*

- លាងដំបៅឲ្យបានស្អាតជាមួយសាប៊ូនិងទឹកឆ្អិនត្រជាក់ ដើម្បីឲ្យរបកក្រមរ។ ធ្វើដូចនេះរាល់ថ្ងៃ រហូតទាល់តែអស់ខ្ទុះ។
- ទុកដំបៅតូចៗទាំងនោះឲ្យត្រូវខ្យល់។ រុំដំបៅធំៗ ហើយផ្លាស់ស្បៃរុំឲ្យបានញឹកញាប់។
- បើស្បែកនៅជុំវិញដំបៅឡើងក្រហមនិងក្ដៅ ឬបើអ្នកជំងឺមានគ្រុនក្ដៅ មានស្នាមក្រហមចេញពីដំបៅ ឬមានហើមកូនកណ្ដុរ ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ដូចជាប៉េនីស៊ីលីនគ្រាប់(ទំ.៣៥៥) ឬថ្នាំស៊ុលហ្វាគ្រាប់(ទំ៣៦២)។
- កុំអេះដំបៅ។ ការអេះដំបៅធ្វើឲ្យដំបៅកាន់តែរីកធំ ហើយអាចឆ្លងរាលដាលទៅផ្នែកដទៃទៀតនៃខ្លួនប្រាណ។ កាត់ក្រចកដៃរបស់កុមារតូចៗឲ្យខ្លីបំផុត។ ឬពាក់ស្រោមដៃឲ្យពួកគេ ដើម្បីកុំឲ្យអេះបាន។
- កុំឲ្យកុមារដែលមានដំបៅ ឬមានការបង្ករោគលើស្បែកផ្សេងៗ លេងឬដេកជាមួយកុមារដទៃទៀត។ ការបង្ករោគទាំងនេះ ងាយឆ្លងរាលដាលណាស់។

## ពងបែក



នេះគឺជាការបង្ករោគដោយបាក់តេរីដែលធ្វើឲ្យមានដំបៅពណ៌លឿងរលោង ហើយឆ្លងរាលដាលយ៉ាងឆាប់រហ័ស។ វាច្រើនកើតនៅលើមុខរបស់កុមារ ជាពិសេសនៅជុំវិញមាត់។ ពងបែកអាចឆ្លងយ៉ាងងាយទៅមនុស្សផ្សេងទៀត តាមរយៈដំបៅ ឬម្រាមដៃកខ្វក់។

*វិធីព្យាបាល*

- លាងសម្អាតដំបៅជាមួយសាប៊ូនិងទឹកឆ្អិនត្រជាក់ ៣ទៅ៤ដងក្នុងមួយថ្ងៃ ដើម្បីយកក្រមរចេញដោយថ្នមៗ។
- រាល់ពេល បន្ទាប់ពីលាងសម្អាតដំបៅរួច លាបដំបៅនឹងថ្នាំហ្សង់ទីយ៉ានវីយូឡេ(ទំ.៣៧១) ឬលាបក្រមួនថ្នាំអង់ទីប៊ីយូទិក ដែលមានជាតិបាក់ស៊ីត្រាស៊ីន ដូចជាប៉ូលីស្ពូរីន(ទំ.៣៧១)។
- បើការបង្ករោគរាលដាលកាន់តែធំទៅៗ ឬធ្វើឲ្យមានគ្រុនក្តៅ ឲ្យថ្នាំគ្រាប់ប៉េនីស៊ីលីន(ទំ.៣៥៥)។ បើអ្នកជំងឺមានប្រតិកម្មជាមួយថ្នាំប៉េនីស៊ីលីន ឬថ្នាំនេះហាក់ដូចជាមិនអាចជួយបាន ឲ្យថ្នាំអេរីត្រូមីស៊ីន(ទំ.៣៥៨) ឬកូទ្រីមម៉ុកសាសូល(ទំ.៣៥៨)ជំនួសវិញ។

*ការបង្ការ*

- ធ្វើតាមសេចក្តីណែនាំអំពីការរក្សាអនាម័យផ្ទាល់ខ្លួន(ទំ.១៣៣)។ ងូតទឹកឲ្យកុមាររៀងរាល់ថ្ងៃ និងការពារពួកគេពីសង្កើច ឬសត្វល្អិតខាំ។ បើកុមារកើតកមរមាស់ ព្យាបាលពួកគេឲ្យបានរហ័សបំផុតតាមដែលអាចធ្វើបាន។
- កុំឲ្យកុមារដែលកើតដំបៅពងបែក ដេកឬលេងជាមួយកុមារដទៃ។ ចាប់ផ្តើមព្យាបាលនៅពេលមានរោគសញ្ញាដំបូង។

## ជំងឺយ៉ស៍ (Yaws)

យ៉ស៍ គឺជាការបង្ករោគមួយដោយបាក់តេរី ដែលអ្នកសង្កេតឃើញដំបូងដោយមានការចេញដុំពកដែលមិនឈឺចាប់ និងបន្តរីកធំទៅៗ ហើយអាចឆ្លងរាលដាលបន្តិចបន្តួច។ បន្ទាប់ពីបានប្រហែល៦ខែ ដុំពកនោះក៏បាត់ទៅវិញ។ ជាច្រើនខែឬច្រើនឆ្នាំក្រោយមក វាក៏កើតឡើងវិញ រាលដាលខ្លាំងជាងមុន និងអាចមានហូរខ្ទុះ។ នេះគឺជាពេលដែលវាអាចឆ្លងទៅអ្នកដទៃទៀតបាន។ រោគសញ្ញាទាំងនេះក៏អាចនឹងបាត់ទៅវិញទៀតដែរ។ ប៉ុន្តែបើគ្មានការព្យាបាលទេ ៥ឬ១០ឆ្នាំក្រោយការបង្ករោគយ៉ស៍ អាចរាលដាលពេញខ្លួន ធ្វើឲ្យគ្រោះថ្នាក់ដល់ឆ្អឹង សន្លាក់ និងបណ្តាលឲ្យមានបញ្ហាផ្សេងៗទៀត។

*ការព្យាបាល*

- ទោះបីជាបាក់តេរីដែលបង្កជំងឺយ៉ស៍មានទំនាក់ទំនងជាមួយជំងឺស្វាយក៏ដោយ វាឆ្លងតាមការប៉ះពាល់ មិនមែនតាមការរួមភេទទេ។ ជំងឺយ៉ស៍ត្រូវបានធ្វើតេស្ត៍និងព្យាបាលដោយប្រើថ្នាំនិងកម្រិតប្រើប្រាស់ដូចគ្នានឹងជំងឺស្វាយដែរ (មើលទំ.២៣៧ ទៅ២៣៨)។

## បូស និងអាប់សែ



បូស ឬអាប់សែ គឺជាការបង្ករោគមួយ ដែលបង្កជាថង់ខ្ទុះមួយនៅក្រោមស្បែក។ វាអាចកើតឡើងនៅពេលដែលឬសនៃរោមមានការបង្ករោគ។ ឬវាអាចបណ្តាលមកពីមានរបួស ឬមានការបង្ករោគពីការចាក់ថ្នាំដោយប្រើម្ជុលកខ្វក់។ បូសធ្វើឲ្យមានការឈឺចាប់យ៉ាងខ្លាំង ហើយស្បែកនៅជុំវិញវាឡើងក្រហមនិងក្តៅ។ វាអាចធ្វើឲ្យហើមកូនកណ្តុរ និងមានគ្រុនក្តៅ។

*ការព្យាបាល*

- ស្អំនៅលើបូសដោយក្រណាត់ជ្រលក់ទឹកក្តៅ ជាបានច្រើនដងក្នុងមួយថ្ងៃ(មើលទំ.១៩៥)។
- ទុកឲ្យបូសធ្លាយដោយខ្លួនវា។ បន្ទាប់ពីធ្លាយហើយ បន្តស្អំដោយក្រណាត់ក្តៅ។ ទុកឲ្យខ្ទុះហូរចេញ កុំច្របាច់ឬសង្កត់វា ព្រោះវាអាចធ្វើឲ្យការបង្ករោគឆ្លងរាលដាលទៅផ្នែកដទៃទៀតនៃខ្លួនប្រាណ។
- បើអាប់សែមានការឈឺចាប់ខ្លាំង ហើយមិនធ្លាយចេញបន្ទាប់ពីត្រាំទឹកក្តៅ២ឬ៣ថ្ងៃទេ គេអាចត្រូវការបើកមុខវា ដើម្បីឲ្យខ្ទុះហូរចេញមកក្រៅ។ ការធ្វើរបៀបនេះអាចបន្ថយការឈឺចាប់យ៉ាងឆាប់រហ័ស។ បើអាច រកជំនួយពីគ្រូពេទ្យ។
- បើបូសធ្វើឲ្យហើមកូនកណ្តុរឬមានគ្រុនក្តៅ លេបថ្នាំប៉េនីស៊ីលីនគ្រាប់(ទំ.៣៥១) ឬអេរីត្រូមីស៊ីន(ទំ.៣៥៥)។

# កន្ទួលក្រហម រមាស់ ឬកន្ទាលត្រអាក (ប្រតិកម្មទំនាស់លើស្បែក)



ការប៉ះពាល់ ការបរិភោគ ការចាក់ថ្នាំ ឬការដកដង្ហើមចូលសារធាតុមួយចំនួន អាចបណ្តាលឲ្យកើតកន្ទួលក្រហមរមាស់ ឬកន្ទាលត្រអាក ចំពោះអ្នកដែលមានប្រតិកម្មទំនាស់។ សម្រាប់ព័ត៌មានលម្អិត មើលប្រតិកម្មទំនាស់ នៅទំ.១៦៦។

កន្ទាលត្រអាកគឺជាការឡើងកន្ទួលក្រាស់ៗ ពណ៌ក្រហម ដែលមើលទៅដូចជាស្នាមឃ្មុំទិច ហើយរមាស់យ៉ាងខ្លាំង។ វាអាចកើតឡើងហើយបាត់ទៅវិញយ៉ាងរហ័ស ឬផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយទៀត។

ប្រុងប្រយ័ត្នចំពោះប្រតិកម្មដែលបណ្តាលមកពីថ្នាំមួយចំនួន ជាពិសេសការចាក់ថ្នាំប៉េនីស៊ីលីន និងថ្នាំប្រឆាំងពិស ឬថ្នាំអង់ទីតូស៊ីន ដែលធ្វើពីសេរ៉ូមសេះ។ កន្ទួលក្រហមរមាស់ ឬកន្ទាលត្រអាក អាចចេញក្នុងរយៈពេលពីរបីនាទី រហូតដល់ ១០ថ្ងៃ បន្ទាប់ពីការចាក់ថ្នាំរួច។

**បើអ្នកមានកន្ទួលក្រហមរមាស់ កន្ទាលត្រអាក ឬប្រតិកម្មផ្សេងៗ បន្ទាប់ពីបានលេប ឬចាក់ថ្នាំអ្វីមួយ ឈប់ប្រើថ្នាំនោះភ្លាម ហើយមិនត្រូវប្រើថ្នាំនោះតទៅទៀតក្នុងមួយជីវិតរបស់អ្នក!** ការធ្វើរបៀបនេះមានសារសំខាន់ណាស់ដើម្បីបង្ការគ្រោះថ្នាក់នៃស្អុកអាល់ឡេស៊ី(ទំ.៧០)។

*វិធីព្យាបាលរមាស់*

- ងូតទឹកត្រជាក់ ឬស្អំដោយក្រណាត់ជ្រលក់ទឹកត្រជាក់ឬទឹកកក។
- ការស្អំដោយទឹកអង្ករត្រជាក់ ក៏អាចបន្ថយការរមាស់បានដែរ។ ស្ងោរអង្ករក្នុងទឹក ចាក់យកទឹករបស់វា ហើយទឹកនោះ ពេលវាត្រជាក់។
- បើរមាស់ខ្លាំងពេក ប្រើថ្នាំប្រឆាំងអ៊ីស្តាមីន ដូចជាខ្លរហ្វេនីរ៉ាមីន(ទំ.៣៨៥)។



- ដើម្បីការពារទារកកុំឲ្យអេះខ្លួនវា កាត់ក្រចកដៃវាឲ្យខ្លី ឬពាក់ស្រោមដៃឲ្យវា។

# រុក្ខជាតិនិងវត្ថុមួយចំនួនដែលធ្វើឲ្យរមាស់ឬក្រហាយស្បែក

ខ្នុរ ដើមកន្ទិចអាល រុក្ខជាតិមានរោម និងរុក្ខជាតិជាច្រើនទៀត អាចធ្វើឲ្យកើតពងទឹក ក្រហាយ ឬមានកន្ទួលរមាស់ ពេលវាប៉ះជាមួយស្បែកមនុស្ស។ ទឹកមាត់ឬរោមរបស់មេអំបៅ និងសត្វល្អិតប្រភេទខ្លះធ្វើឲ្យមានប្រតិកម្មប្រហែលគ្នានេះដែរ។



ចំពោះអ្នកដែលមានប្រតិកម្មទំនាស់ ការឡើងកន្ទួល ឬផ្ទាំងដំបៅចេញទឹករងៃ អាចបណ្តាលមកពីមានវត្ថុខ្លះប៉ះជាមួយស្បែក។ ស្បែកជើងកៅស៊ូ ខ្សែនាឡិកា ថ្នាំដាក់ត្រចៀក និងថ្នាំពេទ្យខ្លះទៀត ក្រែមលាបមុខ ទឹកអប់ ឬសាប៊ូ ក៏អាចបណ្តាលឲ្យមានបញ្ហាទាំងអស់នេះដែរ។

*វិធីព្យាបាល*

ការរោលក្រហាយទាំងនេះនឹងបាត់ទៅវិញដោយខ្លួនឯង នៅពេលឈប់មានការប៉ះពាល់ជាមួយវត្ថុដែលនាំឲ្យមានបញ្ហាទាំងនោះទៀត។ ម្សៅអង្ករ និងទឹកត្រជាក់អាចបន្ថយការរមាស់បាន។ ថ្នាំអាស្ពីរីន ឬថ្នាំប្រឆាំងអ៊ីស្តាមីន(ទំ.៣៨៦) ក៏អាចជួយបានដែរ។ ក្នុងករណីធ្ងន់ធ្ងរ អ្នកអាចប្រើក្រមួនដែលមានជាតិគ័រទីសូន ឬគ័រទីគូស្តេរ៉ូអ៊ីដ(មើលទំ.៣៧១)។ ដើម្បីបង្ការការបង្ករោគ សម្អាតផ្ទៃដែលមានការរោលក្រហាយនេះ។

## រើមធំ

*រោគសញ្ញា*

ផ្ទាំងពងទឹកដែលមានការឈឺចាប់យ៉ាងខ្លាំង ដែលកើតឡើងភ្លាមៗ នៅចំហៀងណាមួយនៃរាងកាយ អាចជារើមធំ។ កន្លែងដែលវាច្រើនកើតបំផុតគឺ នៅលើខ្នង ទ្រូង ក ឬមុខ។ ជាទូទៅពងទឹកកើតឡើងក្នុងរយៈពេល២ឬ៣អាទិត្យ ហើយបាត់ទៅវិញដោយខ្លួនឯង។ ជួនកាលការឈឺចាប់នៅតែបន្ត ឬមានការឈឺចាប់ឡើងវិញ បន្ទាប់ពីពងទឹកបានបាត់ទៅវិញរយៈពេលយ៉ាងយូរ។



រើមធំបណ្តាលមកពីវីរុសដែលធ្វើឲ្យកើតជំងឺអុតស្វាយ ហើយជាធម្មតាកើតលើមនុស្សដែលធ្លាប់កើតអុតស្វាយពីមុនមក។ វាមិនបណ្តាលឲ្យមានគ្រោះថ្នាក់ទេ។ (ទោះជាយ៉ាងនេះក៏ដោយ ជួនកាលវាក៏អាចជាសញ្ញាព្រមានអំពីបញ្ហាធ្ងន់ធ្ងរដទៃទៀត អាចជាជំងឺមហារីក ឬជំងឺអេដស៍ ទំ.៣៩៩)។

*វិធីព្យាបាល*

- ដាក់ក្រណាត់ស្តើងគ្របលើពងទឹក ដើម្បីកុំឲ្យវាកកិតជាមួយនឹងអាវ។
- លេបថ្នាំអាស្ពីរីនដើម្បីបន្ថយការឈឺចាប់ (ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រយោជន៍ទេ)។

# ស្រែង (ការបង្ករោគដោយមេរោគផ្សិត)

ការបង្ករោគដោយមេរោគផ្សិត អាចកើតឡើងនៅគ្រប់ផ្នែកនៃរាងកាយ ប៉ុន្តែគេច្រើនឃើញមាននៅ ៖

*លលាដ៍ក្បាល (ភ្លឺ)* *កន្លែងដែលគ្មានរោម (ស្រែង)* *ចន្លោះម្រាមជើងឬម្រាមជើង* *ចន្លោះភ្លៅ*



ការបង្ករោគដោយមេរោគផ្សិតភាគច្រើន កើតឡើងជារាងរង្វង់មូល។ វាច្រើនតែមានការរមាស់យ៉ាងខ្លាំង។ ស្រែងនៅលើក្បាលអាចបង្កើតជាផ្ទាំងមូលៗដែលមានរបកក្រមរនិងជ្រុះសក់។ ក្រចកដៃក្រចកជើងដែលមានការបង្ករោគដោយមេរោគផ្សិតលក្លាយទៅជាគ្រើមនិងក្រាស់។

*វិធីព្យាបាល*

- សាប៊ូនិងទឹក។ ការលាងសម្អាតត្រង់កន្លែងដែលមានការបង្ករោគជាមួយសាប៊ូនិងទឹក ជារៀងរាល់ថ្ងៃ អាចជាអ្វីដែលត្រូវការ។ បើធ្វើបាន ប្រើសាប៊ូជាមួយអ៊ិចសាខ្លរ៉ូហ្វែន( ទំ.៣៧០ )។
- ព្យាយាមធ្វើឲ្យកន្លែងដែលមានបញ្ហានោះស្ងួតជានិច្ច ហើយឲ្យត្រូវខ្យល់ ឬពន្លឺថ្ងៃ។ ផ្លាស់ប្តូរខោអាវទ្រនាប់ ឬស្រោមជើងឲ្យបានញឹកញាប់ ជាពិសេសនៅពេលមានការបែកញើស។
- ប្រើក្រមួនស្ពាន់ធ័រ និងខ្លាញ់( ស្ពាន់ធ័រ១ភាគ ខ្លាញ់១០ភាគ )។
- ក្រមួននិងម្សៅលាយជាមួយសាលីស៊ីលិក ឬអង់ឌីស៊ីឡេនិកអាស៊ីត( undecylenic acid ) ឬតុលណាហ្វតាត ( ទីណាក់ទីន Tinactin ទំ.៣៧២ ) អាចជួយព្យាបាលរោគផ្សិតនៅចន្លោះម្រាមដៃ ម្រាមជើង និងចន្លោះភ្លៅបាន។
- ចំពោះស្រែងនៅក្បាលធ្ងន់ធ្ងរ ឬការបង្ករោគដោយមេរោគផ្សិតដែលឆ្លងរាលដាលយ៉ាងខ្លាំង ឬដែលគ្មានការធូរស្រាលបន្ទាប់ពីបានព្យាបាលតាមរបៀបខាងលើនេះ ប្រើថ្នាំគ្រីហ្សេអូហ្វុលវីន ១ក្រាមក្នុង១ថ្ងៃ ចំពោះមនុស្សធំ និងកន្លះក្រាមចំពោះកុមារ( ទំ.៣៧២ )។ បើចាំបាច់ត្រូវលេបថ្នាំនេះជាច្រើនអាទិត្យ ឬច្រើនខែ ដើម្បីបំបាត់ការបង្ករោគនេះជាស្ថាពរ។



- ស្រែងនៅលើក្បាលជាច្រើន អាចបាត់ទៅវិញនៅពេលកុមារធំពេញវ័យ (អាយុ១១ទៅ១៤ឆ្នាំ)។ ការបង្ករោគធ្ងន់ធ្ងរដែលបង្កើតជាផ្ទាំងហើមធំៗ ដោយមានខ្ទុះ គួរតែព្យាបាលដោយការស្អំជាមួយក្រណាត់ជ្រលក់ទឹកក្តៅ( ទំ.១៩៥ )។ វាជាការសំខាន់ណាស់ក្នុងការកោរសក់នៅត្រង់កន្លែងកើតស្រែងនោះឲ្យអស់។ ប្រើគ្រីហ្សេអូហ្វុលវីន បើអាចធ្វើបាន។

*របៀបបង្ការការបង្ករោគដោយមេរោគផ្សិត ៖*

ស្រែងនិងការបង្ករោគដោយមេរោគផ្សិតផ្សេងទៀត មានការឆ្លងរាលដាលយ៉ាងខ្លាំង។ ដើម្បីបង្ការការឆ្លងរាលដាលពីកុមារម្នាក់ទៅកុមារដទៃទៀត ៖

- កុំឲ្យកុមារដែលមានការបង្ករោគដោយមេរោគផ្សិត ដេកជាមួយកុមារផ្សេងទៀត។
- កុំឲ្យកុមារប្រើក្រាស់រួមគ្នា ឬប្រើខោអាវ កន្សែងរួមគ្នា លើកលែងតែបានបោកគក់ ឬសម្អាតត្រឹមត្រូវជាមុនសិន។
- ព្យាបាលកុមារដែលមានការបង្ករោគនេះភ្លាមៗ។

## ចំណុចៗពណ៌សនៅលើមុខនិងខ្លួនប្រាណ

**ភ្លី** គឺជាការបង្ករោគដោយមេរោគផ្សិតដែលមានសភាពស្រាល ដែលបណ្តាលឲ្យកើតមានចំណុចតូចៗ ពណ៌ចាស់ឬខ្ចី ហើយមានរាងខុសៗគ្នា ដែលភាគច្រើនឃើញកើតនៅលើទ្រូង ក និងខ្នង។ ចំណុចទាំងនេះ អាចមានក្រមរហុយៗបន្តិចបន្តួច ប៉ុន្តែមិនរមាស់ទេ។ រោគនេះមិនបណ្តាលឲ្យមានគ្រោះថ្នាក់ទេ។



*វិធីព្យាបាល*

- ធ្វើក្រមួនដោយលាយស្ពាន់ធ័រជាមួយខ្លាញ់(ស្ពាន់ធ័រ១ភាគ និងខ្លាញ់១០ភាគ) ហើយលាបខ្លួនទាំងមូល រាល់ថ្ងៃ រហូតជា។ ឬអាចប្រើក្រមួនប្រឆាំងមេរោគផ្សិត (ទំ.៣៧២)។
- សូដ្យូម ធ្យូស៊ុលហ្វាត មានប្រសិទ្ធភាពល្អជាង។ នេះគឺជាថ្នាំដែលអ្នកថតរូបប្រើសម្រាប់លាងហ្វីល។ លាយថ្នាំនេះមួយស្លាបព្រាបាយក្នុងទឹកមួយកែវ រួចលាបលើខ្លួនមួយកំណាត់លើឲ្យសព្វ។ បន្ទាប់មកជូតស្បែកចេញដោយប្រើសំឡីជ្រលក់ទឹកខ្មេះ។
- ដើម្បីបង្ការការកើតឡើងវិញ គេចាំបាច់ត្រូវធ្វើការព្យាបាលតាមរបៀបនេះឡើងវិញ រៀងរាល់ពីរអាទិត្យម្តង។
- សេឡេន្យូម ស៊ុលហ្វីត (ទំ ៣៧២) ឬ Whitfield's ointment ក៏អាចជួយដែរ។



**មានចំណុចតូចៗពណ៌សម៉្យាងទៀត**ដែលច្រើនកើតនៅលើថ្ពាល់កុមារស្បែកខ្មៅដែលនៅហាលក្តៅយូរ។ វាមិនគែមច្បាស់ដូចរោគភ្លីទេ។ ចំណុចទាំងអស់នេះមិនមែនជាការបង្ករោគ និងគ្មានគ្រោះថ្នាក់អ្វីទេ។ តាមធម្មតាវាបាត់ទៅវិញនៅពេលដែលកុមារនោះធំឡើង។ មិនត្រូវប្រើសាប៊ូច្រើនទេ ។ លាបប្រេង។ មិនត្រូវការការព្យាបាលផ្សេងទៀតទេ។

ផ្ទុយពីគំនិតភាគច្រើន ចំណុចពណ៌សៗទាំងអស់នេះមិនមែនជារោគសញ្ញានៃភាពស្លេកស្លាំងនោះទេ។ វានឹងមិនបាត់ដោយការប្រើថ្នាំកម្លាំង ឬថ្នាំវីតាមីនឡើយ។ ចំណុចដែលចេញតែនៅលើថ្ពាល់ មិនត្រូវការព្យាបាលអ្វីទាំងអស់។

*ប្រយ័ត្ន ៖* ជួនកាល ស្នាមអុចៗដែលមានពណ៌ស្លេកស្លាំងអាចជារោគសញ្ញាដំបូងនៃ**ជំងឺឃ្លង់**(ទំ.១៩១)។ ស្នាមអុចៗរបស់ជំងឺឃ្លង់មិនសុទ្ធតែមានពណ៌សទេ ហើយអាចមិនសូវមានញាណដឹងនៅពេលគេចាក់ដោយម្ជុល។ បើជំងឺឃ្លង់កើតឡើងញឹកញាប់ក្នុងតំបន់របស់អ្នក យកកុមារទៅទទួលការពិនិត្យ។

## ឃ្លង់ល្ពៅ



ចំពោះមនុស្សមួយចំនួន កន្លែងខ្លះនៃស្បែករបស់គេមានការបាត់បង់ ពណ៌ពីធម្មជាតិរបស់វា។ បន្ទាប់មក ក៏មានផ្ទៃងពណ៌សលេចឡើង។ បញ្ហាទាំងនេះកើតមានជាញឹកញាប់បំផុតនៅលើដៃជើង មុខ និងផ្នែកខាងលើនៃដងខ្លួន។ ការបាត់បង់ពណ៌ពីធម្មជាតិរបស់ស្បែកនេះ ដែលគេហៅថា "ឃ្លង់ល្ពៅ"នោះ មិនមែនជាជំងឺទេ។ យើងអាចប្រៀបធៀបវាទៅនឹងសក់ស្កូវរបស់មនុស្សចាស់ដែរ។ គ្មានការព្យាបាលណាអាចជួយបានទេ ហើយក៏មិនត្រូវការការព្យាបាលដែរ ប៉ុន្តែកន្លែងស្បែកដែលមានពណ៌សនោះ គួរត្រូវបានការពារពីពន្លឺព្រះអាទិត្យ ដោយការពាក់អាវដៃវែង ឬលាបក្រមួនអុកស៊ីតដីហ្សាំង។ ម៉្យាងទៀត ក្រមួនពណ៌ពិសេសម៉្យាងអាចជួយធ្វើឲ្យចំណុចទាំងនោះមិនសូវមើលឃើញច្បាស់។

## មូលហេតុផ្សេងទៀតនៃផ្ទាំងស្បែកពណ៌ស



មានជំងឺខ្លះអាចធ្វើឲ្យមានផ្ទាំងពណ៌សលើស្បែក ដែលមើលទៅដូចឃ្លង់ល្ពៅដែរ។ ផ្ទាំងស្បែកពណ៌សដែលគេចាក់នឹងម្ជុល ហើយគ្មានការឈឺចាប់នោះ គឺប្រហែលជាជំងឺឃ្លង់( ទំ.១៩៣ )។

ការបង្ករោគមួយចំនួនដោយមេរោគផ្សិតក៏អាចបណ្តាលឲ្យមានផ្ទាំងពណ៌សលើស្បែកដែរ ( មើលភ្លឺ )។

កុមារដែលមានការបាត់បង់ពណ៌ស្បែក និងពណ៌សក់ អាចបណ្តាលមកពីការខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ( ខ្វាស្យគ័រ ទំ.១១២-១១៣ )។

## ជាំមុខពេលមានផ្ទៃពោះ



ក្នុងពេលមានផ្ទៃពោះ ស្ត្រីជាច្រើនមានផ្ទាំងពណ៌ចាស់រាងពងក្រពើ នៅលើស្បែកមុខ ដោះ និងផ្នែកខាងក្រោមនៃពោះ។ ជួនកាលវាបាត់ ទៅវិញ បន្ទាប់ពីសម្រាលកូនរួច ជួនកាលទៀតវាមិនបាត់ទេ។ ជួនកាល ស្នាមទាំង នេះក៏អាចកើតលើស្ត្រីដែលអំឡុងពេលប្រើថ្នាំគ្រាប់ពន្យារកំណើតដែរ។

ស្នាមទាំអស់នេះ គឺជាការធម្មតា ហើយវាមិនមែនជាសញ្ញានៃភាពខ្សោយ ឬជំងឺទេ។ គេមិនត្រូវការការព្យាបាលអ្វីទេ។

# ការប្រេះបែកស្រកា និងជំងឺសើស្បែកផ្សេងៗទៀត ដែលបណ្ដាលមកពីកង្វះអាហារូបត្ថម្ភ

បញ្ហាប្រេះបែកស្រកា គឺជាទម្រង់មួយនៃកង្វះអាហារូបត្ថម្ភ ដែលប៉ះពាល់ដល់ស្បែក និងជួនកាលប៉ះពាល់ដល់ប្រព័ន្ធរំលាយអាហារ និងប្រព័ន្ធសរសៃប្រសាទ។ បញ្ហានេះកើតឡើងជាញឹកញាប់នៅតំបន់ដែលប្រជាជនបរិភោគពោត ឬអាហារជាតិម្សៅយ៉ាងច្រើន ហើយមិនបានបរិភោគគ្រប់គ្រាន់នូវសណ្ដែក សាច់ ត្រី ស៊ុត បន្លែ និងអាហារស្ថាបនានិងការពាររាងកាយដទៃទៀត (មើលទំ.១១០)។

*រោគសញ្ញានៅលើស្បែកក្នុងបញ្ហាកង្វះអាហារូបត្ថម្ភ ៖*

ចំពោះមនុស្សធំដែលមានស្បែកប្រេះបែកស្រកា ស្បែករបស់គេទៅជាស្ងួត និងប្រេះ។ ស្បែកនោះរបកដូចជាស្បែកដែលបានរលាកដោយកម្ដៅថ្ងៃនៅកន្លែងស្បែកដែលត្រូវពន្លឺថ្ងៃ ជាពិសេសនៅ ៖




ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភ ស្បែកនៅជើង (និងជួនកាល ស្បែកនៅដៃ) អាចមានចំណុចខ្មៅៗ ដូចជាមានការខ្លាំ ឬមានដំបៅរបក។ កជើង និងជើង អាចឡើងហើម(មើលទំ.១១៣)។




នៅពេលមានបញ្ហាទាំងអស់នេះកើតឡើង ជាញឹកញាប់ វាក៏មានរោគសញ្ញាផ្សេងៗទៀតនៃកង្វះអាហារូបត្ថម្ភ ដូចជាហើមពោះ ដំបៅនៅគែមមាត់ អណ្ដាតពណ៌ក្រហមនិងមានដំបៅ ខ្សោយ មិនឃ្លានអាហារ មិនឡើងទម្ងន់។ល។ (មើលជំពូក១១ ទំ.១១២ និងទំ.១១៣)។

*វិធីព្យាបាល*

- ការបរិភោគអាហារប៉ប៉នរាងកាយ អាចព្យាបាលបញ្ហាប្រេះបែកស្រកានេះ។ ជារៀងរាល់ថ្ងៃ អ្នកជំងឺគួរព្យាយាមបរិភោគសណ្ដែក ឬសាច់មាន់ ស៊ុត សាច់ សាច់ត្រី។ បើមានជំរើស គួរប្រើអង្ករជំនួសពោតវិញ។
- ចំពោះករណីប្រេះស្រកាធ្ងន់ធ្ងរ និងទម្រង់ដទៃទៀតនៃកង្វះអាហារូបត្ថម្ភ ការប្រើវីតាមីនអាចជួយបាន ប៉ុន្តែ **អាហារល្អ មានសារសំខាន់ជាង**។ ត្រូវប្រាកដថា ថ្នាំវីតាមីនដែលអ្នកប្រើនោះ គួរសំបូរវីតាមីនបេ ជាពិសេស នីយ៉ាស៊ីន។ គ្រប់ប៉ែគឺជាប្រភពដ៏ល្អនៃវីតាមីនបេ។

*មុនពេលបរិភោគត្រឹមត្រូវ*



ការហើម និងចំណុចខ្មៅៗនៅលើប្រអប់ជើង និងជើងរបស់បុរសម្នាក់នេះ គឺជាលទ្ធផលនៃកង្វះអាហារូបត្ថម្ភ។ បុរសម្នាក់នេះភាគច្រើនមិនបានបរិភោគអាហារដែលសំបូរជាតិប្រូតេអ៊ីន និងវីតាមីនផ្សេងៗទេ។ *(រូបភាពពី Weinsier, R.L. Fundamentals of Clinical Nutrition. New York: Mosby Year Books; 1993.)*

*បន្ទាប់ពីបានបរិភោគត្រឹមត្រូវ*



បន្ទាប់ពីគាត់បានទទួលវីតាមីនត្រឹមត្រូវ ការហើម បានបាត់ទៅវិញ ហើយចំណុចខ្មៅៗក៏ស្ទើរតែបាត់អស់ដែរ។ *(រូបភាពពី Weinsier, R.L. Fundamentals of Clinical Nutrition. New York: Mosby Year Books; 1993.)*

## ឬស

ឫសភាគច្រើន ជាពិសេសឫសដែលកើតលើកុមារ ក្នុងរយៈពេលពី៣ទៅ៥ឆ្នាំ ហើយនឹងបាត់ទៅវិញដោយឯកឯង។ ចំណុចរាបស្មើដែលដូចឫស ហើយមានការឈឺចាប់ ដែលចេញនៅបាតជើង ភាគច្រើនគឺជា "ឫសបាតចើង"។ (ឬវាអាចជាការក្រស់។ មើលខាងក្រោមនេះ)។



*វិធីព្យាបាល*

- ការព្យាបាលដោយវេទមន្ត ឬការព្យាបាលតាមផ្ទះ ភាគច្រើនអាចព្យាបាលឫសបានដែរ។ ប៉ុន្តែដើម្បីសុវត្ថិភាព គេគប្បីកុំប្រើអាស៊ីដ ឬរុក្ខជាតិពុលខ្លាំងពេក ព្រោះវាអាចបណ្ដាលឲ្យមានការរលាក មានដំបៅ ដែលអាចជាបញ្ហាធ្ងន់ធ្ងរជាងឫសទៅទៀត។
- ជួនកាលបុគ្គលិកសុខាភិបាលអាចបំបាត់ឫសបាតជើងបាន។
- សម្រាប់ឫសដែលដុះនៅលើប្រដាប់បន្តពូជបុរសឬស្ត្រី មើលទំ.៤០២។

## ក្រស់

ក្រស់គឺជាផ្នែកក្រាស់រឹងនៃស្បែក។ វាកើតឡើងនៅកន្លែងដែលស្បែកជើងប៉ះកកិតជាមួយស្បែក ឬម្រាមជើងមួយសង្កត់ទៅលើម្រាមមួយទៀត។ ក្រស់អាចមានការឈឺចាប់យ៉ាងខ្លាំង។

*វិធីព្យាបាល*

- ពាក់ស្បែកជើងណាដែលមិនសង្កត់ទៅលើកន្លែងដែលក្រស់។
- ដើម្បីបន្ថយការឈឺចាប់របស់ការក្រស់ ធ្វើដូច្នេះ ៖

១. ត្រាំជើងក្នុងទឹកក្ដៅឧណ្ហៗរយៈពេល១៥នាទី។



២. ប្រើប្រដាប់ខាត់ មកខាត់កន្លែងក្រស់រហូតដល់ស្ដើងវិញ។



៣. ទ្រាប់ជើង ជុំវិញកន្លែងដែលក្រស់ ដើម្បីកុំឲ្យវាសង្កត់កកិតទៅលើស្បែកជើង ឬម្រាមជើង។ រុំជើងឬម្រាមជើងដោយក្រណាត់ទន់ៗ រួចចោះរន្ធជុំវិញកន្លែងក្រស់។



## មុន និងអាចម៍រុយ



មនុស្សវ័យក្មេង ជួនកាលមានមុននៅលើមុខ ទ្រូង ឬខ្នង ជាពិសេសប្រសិនបើស្បែករបស់ពួកគេមានជាតិប្រេងច្រើនពេក។ មុនគឺជាពងតូចៗដែលបង្កើតបានជាដុំខ្ទុះ ឬដុំពណ៌ខ្មៅៗ។ ជួនកាលវាអាចក្លាយជាដំបៅយ៉ាងធំ។

*ការព្យាបាល ៖*

- លាងសម្អាតមុខពីរដងក្នុងមួយថ្ងៃ ជាមួយសាប៊ូ និងទឹកក្ដៅឧណ្ហៗ។
- កក់សក់រៀងរាល់ពីរថ្ងៃម្ដង ប្រសិនបើអាច។
- ពន្លឺថ្ងៃអាចជួយបំបាត់មុនបានដែរ។ ដាក់កន្លែងដែលកើតមុននោះឲ្យត្រូវពន្លឺថ្ងៃ។
- បរិភោគឲ្យបានល្អ តាមដែលអាចធ្វើបាន ផឹកទឹកឲ្យច្រើន និងដេកឲ្យបានគ្រប់គ្រាន់។
- កុំប្រើប្រេងលាបស្បែកឬប្រេងលាបសក់ ដែលមានជាតិក្រមួន ប្រេង ឬខ្លាញ់។
- មុនពេលចូលដេក លាយអាល់កុល១០ភាគ ជាមួយនឹងស្ពាន់ធ័រ១ភាគ យកមកលាបមុខ។
- ចំពោះករណីធ្ងន់ធ្ងរដែលមានដុំពងខ្ទុះ ប្រសិនបើមិនបានធូរស្រាលដោយការប្រើវិធីដែលបានរៀបរាប់ខាងលើនេះទេ ថ្នាំតេត្រាស៊ីក្លីនអាចជួយបាន។ លេបម្ដង១គ្រាប់ ៤ដងក្នុង១ថ្ងៃ រយៈពេល៣ថ្ងៃ បន្ទាប់មកលេប២គ្រាប់ក្នុង១ថ្ងៃរាល់ថ្ងៃ។ ជួនកាលគេចាំបាច់ត្រូវលេប១ឬ២គ្រាប់រាល់ថ្ងៃ រយៈពេលជាច្រើនខែ។

## មហារីកស្បែក

មហារីកស្បែកច្រើនកើតចំពោះអ្នកដែលមានស្បែកស ដែលត្រូវពន្លឺថ្ងៃយូរ។ វាច្រើនកើតនៅកន្លែងដែលត្រូវពន្លឺថ្ងៃខ្លាំងជាងគេ ជាពិសេស ៖




មហារីកស្បែកអាចមានច្រើនសណ្ឋាន។ ជាទូទៅ វាចាប់ផ្ដើមឡើងដោយមានដុំមូលតូចមួយ មានពណ៌ដូចគុជខ្យង ហើយមានប្រហោងមួយនៅកណ្ដាល។ វារីកធំបន្តិចម្ដងៗ។

**មហារីកស្បែកភាគច្រើនពុំមានគ្រោះថ្នាក់ទេ ប្រសិនបើព្យាបាលទាន់ពេល។** គេអាចត្រូវការការវះកាត់ដើម្បីយកវាចេញ។ ប្រសិនបើអ្នកមានដំបៅរ៉ាំរ៉ៃ ដែលអាចជាមហារីកស្បែក ជួបពិភាក្សាជាមួយបុគ្គលិកសុខាភិបាល។

ដើម្បីបង្ការជំងឺមហារីកស្បែក អ្នកដែលមានស្បែកស គួរការពារខ្លួនពីពន្លឺថ្ងៃ និងពាក់មួកជានិច្ច។ អ្នកមានជំងឺមហារីកស្បែក ហើយត្រូវធ្វើការនៅក្រោមកម្ដៅថ្ងៃ គួរតែទិញក្រែមពិសេសម្យ៉ាងសម្រាប់លាបការពារពួកគេ។ ក្រមួនអុកស៊ីដដីហ្សាំងមានតម្លៃថោក ហើយមានប្រសិទ្ធភាពទៀតផង។

# របេងស្បែក ឬរបេងកូនកណ្ដុរ

មេរោគដែលបណ្ដាលឲ្យកើតជំងឺរបេងសួត ជួលកាលក៏អាចប៉ះពាល់ដល់ស្បែកដែរ ដោយមិនធ្វើឲ្យមានការឈឺចាប់ទេ។

*ដុំពក ដែលធ្វើឲ្យខូចទ្រង់ទ្រាយ* *ផ្ទាំងដំបៅរុំារ៉ៃ* *ដំបៅស្បែក* *ឬ* *ឫសដំៗ*



ជាទូទៅ ជំងឺរបេងស្បែកមានការលូតលាស់យឺតៗ រយៈពេលយ៉ាងយូរ ហើយតែងតែកើតឡើងវិញក្នុងរយៈពេលជាច្រើនខែ ឬច្រើនឆ្នាំ។




ម្យ៉ាងទៀត ជំងឺរបេងជួនកាលប៉ះពាល់ដល់កូនកណ្ដុរ ភាគច្រើននៅក ឬនៅខាងក្រោយឆ្អឹងដងកាំបិត ដែលនៅចន្លោះកនិងស្មា។ កូនកណ្ដុរក៏រីកធំធ្លាយ ហូរខ្ទុះ ហើយជិតមុខវិញមួយរយៈពេល បន្ទាប់មកក៏ធ្លាយនិងហូរខ្ទុះទៀត។ តាមធម្មតា**វាមិនឈឺចាប់ទេ**។

*វិធីព្យាបាល ៖*

ក្នុងករណីមានដំបៅរុំារ៉ៃ ឬហើមកូនកណ្ដុរ ជាការប្រសើរគួរតែរកជំនួយពីគ្រូពេទ្យ។ គេប្រហែលជាត្រូវធ្វើតេស្ដ៍ ដើម្បីរកមូលហេតុរបស់វា។ ជំងឺរបេងស្បែកត្រូវការការព្យាបាលដូចជំងឺរបេងសួតដែរ (មើលទំ.១៨០)។ ដើម្បីបង្ការការកើតឡើងវិញ គេត្រូវលេបថ្នាំជាច្រើនខែបន្ទាប់ពីស្បែកមើលទៅហាក់ដូចជាល្អវិញហើយក៏ដោយ។

# អេរីស៊ីប៉ែល ( Erysipelas ) និងការរលាកកោសិកា



អេរីស៊ីប៉ែលគឺជាការបង្ករោគស្រួចស្រាល់នៅស្បែក ហើយមានការឈឺចាប់យ៉ាងខ្លាំង។ វាបង្កើតបានជាផ្ទាំង ហើម ក្ដៅ ពណ៌ក្រហមភ្លឺ និងមានគែមច្បាស់ៗ។ ផ្ទាំងនេះរីករាលដាលយ៉ាងឆាប់រហ័សនៅលើស្បែក។ ភាគច្រើនវាចាប់ផ្ដើមនៅ លើមុខ នៅគែមស្លាបច្រមុះ។ បញ្ហានេះតែងតែបណ្ដាលឲ្យមានការហើមកូនកណ្ដុរ គ្រុនក្ដៅនឹងញាក់។

ការរលាកកោសិកា ក៏ជាការបង្ករោគស្រួចស្រាល់នៅស្បែក ដែលមានការឈឺចាប់ យ៉ាងខ្លាំង ដែលអាចកើតឡើងនៅគ្រប់កន្លែងទាំងអស់នៃរាងកាយ។ វាច្រើនតែ កើតឡើងបន្ទាប់ពីមានការដាច់រហែកស្បែក។ ការបង្ករោគនេះមានជម្រៅជ្រៅ និង មានគែមមិនសូវច្បាស់ដូចអេរីស៊ីប៉ែលទេ។

*វិធីព្យាបាល ៖*

ចំពោះអេរីស៊ីប៉ែល និងការរលាកកោសិកា ចាប់ផ្ដើមព្យាបាលឲ្យបានឆាប់ដែលអាចធ្វើបាន។ ប្រើអង់ទីប៊ីយ៉ូទិក ៖ ប៉េនីស៊ីលីនគ្រាប់ ៤០០.០០០អ៊ុយនីតេ ៤ដងក្នុង១ថ្ងៃ។ ក្នុងករណីធ្ងន់ធ្ងរ ចាក់ប្រូកាអ៊ីនប៉េនីស៊ីលីន ៨០០.០០០ អ៊ុយនីតេ រាល់ថ្ងៃ(មើលទំ.៣៥៣)។ បន្តការព្យាបាលដោយអង់ទីប៊ីយ៉ូទិក២ថ្ងៃ បន្ទាប់ពីបាត់រោគសញ្ញានៃការបង្ករោគ។ លើសពីនេះទៀត ប្រើកុំប្រេសក្ដៅដើម្បីស្អំ និងប្រើថ្នាំអាស្ពីរីនសម្រាប់បន្ថយការឈឺចាប់ផងដែរ។

## ដំបៅរលួយ



នេះគឺជាការបង្ករោគដ៏គ្រោះថ្នាក់នៃដំបៅ ដែលក្នុងនោះមានការបង្កើតបានជាខ្ទុះ ពណ៌ប្រផេះ ឬពណ៌ត្នោតដែលមានក្លិនស្អុយ។ ស្បែកដែលនៅជុំវិញដំបៅនោះ អាចមានពងទឹកពណ៌ខ្មៅ ហើយសាច់ដំបៅអាចមានពពុះខ្យល់។ ការបង្ករោគនេះចាប់ផ្តើមមានក្នុងរយៈពេលពី៦ម៉ោង ទៅ៣ថ្ងៃ បន្ទាប់ពីមានរបួស។ វាក្លាយជាធ្ងន់ធ្ងរ និងរាលដាលយ៉ាងឆាប់រហ័ស។ បើគ្មានការព្យាបាលទេ វាបណ្តាលឲ្យអ្នកជំងឺស្លាប់ក្នុងរយៈពេលពីរបីថ្ងៃ។

*វិធីព្យាបាល ៖*

- បើកមុខរបួសឲ្យធំតាមការចាំបាច់។ លាងសម្អាតវាជាមួយទឹកឆ្អិនត្រជាក់ និងសាប៊ូ។ យកសាច់ដុំដែលខូច និងដែលងាប់ចេញ។ បើអាចធ្វើបាន លាងជម្រះមុខរបួសដោយទឹកអ៊ីដ្រូហ្សែនពែរ៉ុកស៊ីត រៀងរាល់ពីរម៉ោងម្តង។
- ចាក់ថ្នាំប៉េនីស៊ីលីន(គ្រីស្តាលីន បើអាច) ១.០០០.០០០អ៊ុយនីតេ រៀងរាល់បីម៉ោងម្តង។
- **ទុកកន្លែងមុខរបួសឲ្យនៅចំហរ ដើម្បីឲ្យវាត្រូវខ្យល់។ រកជំនួយពីគ្រូពេទ្យ។**

## ដំបៅស្បែកដែលបណ្តាលមកពីចលនាឈាមរត់មិនល្អ

ដំបៅស្បែក ឬដំបៅដែលមានមុខចំហរធំ មានមូលហេតុជាច្រើនយ៉ាង(មើលទំ.២០)។ ទោះជាយ៉ាងណាក្តី ដំបៅរ៉ាំរ៉ៃនៅភ្នែកជើងរបស់មនុស្សចាស់ ជាពិសេសចំពោះស្ត្រីដែលមានសរសៃវ៉ែនរីកធំ ជាទូទៅបណ្តាលមកពីចលនាឈាមរត់មិនល្អ។ ឈាមមិនត្រូវបានបញ្ជូនឲ្យបានលឿនគ្រប់គ្រាន់នៅជើង។ ដំបៅនេះអាចក្លាយជាមានទំហំយ៉ាងធំ។ ស្បែកដែលនៅជុំវិញដំបៅមានពណ៌ខៀវចាស់ ភ្លឺរលោង និងស្តើង។ ជាញឹកញាប់ ជើងហើម។



*ការព្យាបាល ៖*



- ដំបៅរបៀបនេះជាសះស្បើយយ៉ាងយឺត ហើយលុះត្រាតែមានការថែទាំយ៉ាងហ្មត់ចត់បំផុត។ សំខាន់បំផុតគឺ **ដាក់ជើងដែលមានដំបៅនោះឲ្យខ្ពស់** ឲ្យបានញឹកញាប់តាមដែលអាចធ្វើបាន។ ដេកដោយដាក់ជើងនោះលើខ្នើយ។ នៅពេលថ្ងៃ សម្រាកដោយលើកជើងនោះឲ្យខ្ពស់ រៀងរាល់១៥នាទីឬ ២០នាទីម្តង។ **ការដើរជួយសម្រាលដល់ចលនាឈាមរត់ ប៉ុន្តែការឈរនៅមួយកន្លែង និងការអង្គុយដាក់ជើងចុះក្រោម ធ្វើឲ្យមានគ្រោះថ្នាក់។**
- ស្អំនៅមុខដំបៅដោយកុំប្រេសក្តៅឧណ្ហៗលាយទឹកអំបិលតិចៗ (អំបិល ១ស្លាបព្រាកាហ្វេ ជាមួយទឹកឆ្អិន១លីត្រ)។ គ្របធូរៗពីលើដំបៅ ដោយកុំប្រេសស្ទេរីល ឬក្រណាត់ស្អាត។ **រក្សាការស្អាតជានិច្ច។**



- ទប់កន្លែងដែលមានសរសៃវ៉ែនរីកធំ ដោយស្រោមជើងយឺត ឬបង់យឺត។ បន្តធ្វើដូច្នេះ និងលើកជើងឲ្យខ្ពស់ បន្ទាប់ពីដំបៅបានជាសះស្បើយ។ ប្រយ័ត្ន កុំអេះ ឬធ្វើឲ្យមានរបួសដល់សន្លាកដែលទើបជាសះស្បើយថ្មីៗនោះ។
- ការព្យាបាលដំបៅនេះដោយប្រើទឹកឃ្មុំឬស្ករ ក៏អាចជួយបានដែរ(មើលទំ.២១៤)។

**ដើម្បីបង្ការដំបៅលើស្បែក ត្រូវផ្តល់ការថែទាំដល់សរសៃវ៉ែនដែលរីកធំឲ្យបានទាន់ពេល (មើលទំ.១៧៥)។**

# ដំបៅគ្រែ

ដំបៅដ៏អាក្រក់ទាំងនេះ កើតឡើងលើមនុស្សដែលឈឺធ្ងន់ ដែលមិនអាចប្រែខ្លួននៅលើគ្រែបាន ជាពិសេសចំពោះមនុស្សចាស់ដែលមានជំងឺ ហើយមានរាងកាយស្គមស្គាំង និងខ្សោយល្វិតល្វៃ។ ដំបៅកើតឡើងនៅត្រង់កន្លែងដែលមានឆ្អឹងពកៗ ដែលស្បែកនៅកន្លែងនោះសង្កត់កកិតជាមួយគ្រែ។ ដំបៅនេះភាគច្រើនឃើញមាននៅកញ្ចុញគូថ ខ្នង ស្មា កែងដៃ ឬជើង។



*វិធីបង្ការដំបៅគ្រែ ៖*

- ប្រែខ្លួនអ្នកជំងឺរៀងរាល់១ម៉ោងម្តង ៖ ដោយឲ្យអ្នកជំងឺដេកផ្ងា ដេកផ្កាប់ និងដេកចំហៀង។
- ងូតទឹកឲ្យគាត់រៀងរាល់ថ្ងៃ ហើយលាបស្បែកជាមួយម្សៅទារក។
- ប្រើកម្រាលគ្រែ និងពូកទន់ៗ។ ប្តូរកម្រាលពូករាល់ថ្ងៃ និងរាល់ពេលដែលប្រឡាក់ដោយទឹកនោម លាមក និងកម្អួត។
- ដាក់ខ្នើយកល់ក្រោមខ្លួនអ្នកជំងឺ ដើម្បីកាត់បន្ថយការកកិតរបស់កន្លែងដែលមានឆ្អឹងពកៗ។



- ផ្តល់អាហារដល់អ្នកជំងឺឲ្យបានត្រឹមត្រូវតាមដែលអាចធ្វើបាន។ បើអ្នកជំងឺបរិភោគមិនសូវបាន ថ្នាំវីតាមីន ឬថ្នាំជាតិដែក អាចជួយបាន (មើលទំ.១១៨)។
- កុមារដែលមានជំងឺធ្ងន់ធ្ងរពុំរ៉ៃ គួរត្រូវបានលើកបីឲ្យបានញឹកញាប់។

*វិធីព្យាបាល ៖*

- ធ្វើតាមការរៀបរាប់ខាងលើ។
- លាងសម្អាតដំបៅដោយទឹកឆ្អិនត្រជាក់និងសាប៊ូ ៣ដងក្នុង១ថ្ងៃ។ យកស្បែកងាប់ចេញដោយថ្នមៗ។ លាងជម្រះដោយទឹកឆ្អិនត្រជាក់។
- ដើម្បីទប់ទល់ជាមួយការបង្ករោគ និងបន្ថែមល្បឿនការជាសះស្បើយ លាបដំបៅដោយទឹកឃ្មុំ ស្ករ ឬទឹកអំពៅ។ ការសំខាន់គឺត្រូវលាងសម្អាត និងលាបដំបៅ យ៉ាងតិច២ដងក្នុង១ថ្ងៃ។ ប្រសិនបើទឹកឃ្មុំឬស្ករ ក្លាយជារាវដោយសារទឹករងៃពីដំបៅ នោះវានឹងចិញ្ចឹមមេរោគទៅវិញទេ គឺមិនមែនសម្លាប់មេរោគឡើយ។

# បញ្ហាស្បែករបស់ទារក

## ការរលាកដោយកន្ទបទឹកនោម



ការមានកន្ទួលក្រហម ក្រហាយ នៅចន្លោះភ្លៅ ឬគូថរបស់ទារក អាចបណ្តាលមកពីការដក់ទឹកនោមនៅកន្ទប ឬក្រណាត់ក្រាលឲ្យទារកដេក។

*វិធីព្យាបាល ៖*

- ងូតទឹកឲ្យទារក ជាមួយទឹកក្តៅឧណ្ហៗនិងសាប៊ូស្រាលៗ ជារៀងរាល់ថ្ងៃ។ ជូតខ្លួនទារកឲ្យស្ងួតដោយថ្នមៗ។
- **ដើម្បីបង្ការឬព្យាបាលកន្ទួលរលាកនេះ គួរដោះសំលៀកបំពាក់ចេញ ដោយមិនប្រើកន្ទប ហើយគួរដាក់ទារកឲ្យត្រូវពន្លឺថ្ងៃ។**




- បើប្រើខោទឹកនោម ផ្លាស់ប្តូរវាឲ្យបានញឹកញាប់។ ក្រោយពេលបោកគក់ខោទឹកនោមរួច លាងវាជាមួយទឹកលាយទឹកខ្មេះបន្តិច។
- ជាការល្អបំផុត មិនត្រូវប្រើម្សៅទេ ប៉ុន្តែបើប្រើ រង់ចាំរហូតដល់បាត់កន្ទួលរមាស់សិន។

## អាចម៍ក្របីលើក្បាលកុមារ



អាចម៍ក្របីគឺជាផ្ទាំងក្រមរជាតិប្រេង ពណ៌លឿង ដែលកើតនៅលើស្បែកក្បាលទារក។ ភាគច្រើនស្បែកក្បាលឡើងក្រហមនិងរោលៗ។ ជាធម្មតាអាចម៍ក្របីកើតដោយសារមិនបានលាងសម្អាតក្បាលរបស់ទារកឲ្យបានញឹកញាប់ ឬមកពីរុំគ្របក្បាលកុមារយូរពេក។

*វិធីព្យាបាល ៖*

- លាងសម្អាតក្បាលរាល់ថ្ងៃ។ ប្រសិនបើអាច ប្រើសាប៊ូដែលមានជាតិថ្នាំ (មើលទំ.៣៧១)។
- លាងសម្អាតអាចម៍ក្របីនិងក្រមរដោយថ្នមៗ។ ដើម្បីលាងសម្អាតក្រមរ ដំបូងត្រូវរុំក្បាលទារកដោយកន្សែងត្រាំទឹកក្តៅឧណ្ហៗសិន។
- ទុកក្បាលកុមារឲ្យ**នៅទទេរ** ឲ្យត្រូវខ្យល់ និងពន្លឺថ្ងៃ។

*មិនត្រូវរុំក្បាលទារកដោយមួកឬក្រណាត់ឡើយ។ មិនត្រូវគ្របក្បាលទារកទេ។*




- បើមានរោគសញ្ញានៃការបង្ករោគ ព្យាបាលដូចពងបែកដែរ(មើលទំ.២០២)។

# ជំងឺត្រអក ( ស្នាមក្រហមដែលមានពងទឹកតូចៗ )

*រោគសញ្ញា ៖*



- ចំពោះកុមារ ៖ ស្នាមក្រហមឬកន្ទួលកើតនៅលើថ្ពាល់ ឬជួនកាល នៅលើដៃនិងប្រអប់ដៃ។ កន្ទួលនេះ មានដំបៅតូចៗ ឬពងទឹកតូចៗ ដែលមាន ចេញទឹកតិចៗ។
- ចំពោះកុមារធំទង់និងមនុស្សធំ ៖ ធម្មតាជំងឺត្រអក មានភាពស្ងួតជាង ហើយភាគច្រើនចេញនៅគន្លាក់ដៃ និងគន្លាក់ជើង។
- វាមិនមែនចាប់ផ្ដើមដូចជាការបង្ករោគទេ ប៉ុន្តែវាដូចជា ប្រតិកម្មអាល់ឡែស៊ីជាង។

*វិធីព្យាបាល ៖*

♦ ស្អំដោយកុំប្រេសត្រជាក់លើកន្លែងដែលមានកន្ទួល។

♦ បើមានរោគសញ្ញានៃការបង្ករោគ( ទំ.៨៨ ) ព្យាបាលដូច ជំងឺពងបែក ដែរ( ទំ.២០២ )។

♦ ដាក់កន្លែងដែលមានស្នាមកន្ទួលនោះឲ្យត្រូវពន្លឺថ្ងៃ។

♦ ក្នុងករណីពិបាក ប្រើក្រែមលាបដែលមានជាតិគរ័ទីហ្សូន ឬគរ័ទីគូស្តេរ៉ូអ៊ីដ( មើលទំ.៣៧១ )។ សូមស្វែងរក ដំបូន្មានពីគ្រូពេទ្យ។

# ជំងឺPsoriasis

*រោគសញ្ញា ៖*



- ស្នាមគ្រើមក្រាស់ ពណ៌ក្រហមឬខៀវលើស្បែក គ្របដណ្ដប់ដោយផ្ទាំងពណ៌សឬពណ៌ទឹកប្រាក់។ ភាគច្រើនស្នាមនេះកើតឡើងត្រង់កន្លែងផ្សេងៗ ដូចបង្ហាញក្នុងរូបគំនូរនេះ។
- តាមធម្មតា ស្ថានភាពជំងឺមានរយៈពេលយូរ ឬ កើតឡើងវិញជានិច្ច។ វាមិនមែនជាការបង្ករោគទេ ហើយក៏មិនមានគ្រោះថ្នាក់ដែរ។

*វិធីព្យាបាល ៖*

♦ ជាញឹកញាប់ ការទុកកន្លែងដែលមានបញ្ហានេះនៅ ចំហរឲ្យ ត្រូវពន្លឺថ្ងៃ អាចជួយបាន។

♦ ជួនកាល ការងូតទឹកសមុទ្រក៏អាចជួយបានដែរ។

♦ រកដំបូន្មានពីគ្រូពេទ្យ។ ការព្យាបាលត្រូវប្រើរយៈពេលយូរ។

♦ ថ្នាំក្រមួនដែលមានជាតិគរ័ទីស្តេរ៉ូអ៊ីដ( ទំ.៣៧១ ) ឬជាតិធ្យូងក៏អាចជួយបានដែរ។